ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០២០ សហវ.[illegible]

ថ្ងៃច័ន្ទ ១០រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី២ ជំហានទី៣ នៅរដ្ឋបាលឃុំ សង្កាត់

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) ដែលបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងដំណាក់កាលទី១ មាន ៣ជំហាន នៅរដ្ឋបាលកណ្តាល សម្រាប់ក្រសួង ស្ថាប័ន ចំនួន២៣ និងមន្ទីរ អង្គភាពជំនាញ ចំនួន១៨ នៅរាជធានី ខេត្ត និងក្នុងដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ និងជំហានទី២ នៅគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាំងអស់រួចមកហើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ NRMIS បន្ថែម ទៅដល់រដ្ឋបាលឃុំ សង្កាត់ នៅដំណាក់កាលទី២ ជំហានទី៣ សម្រាប់រដ្ឋបាលសង្កាត់ ចំណុះរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ និងនៅរដ្ឋបាលឃុំ សង្កាត់ ទូទាំងប្រទេស ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ។

ដើម្បីឱ្យប្រព័ន្ធ NRMIS នេះដំណើរការបានរលូន ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ជ្រាបដូចតទៅ៖

១. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានតម្រូវឱ្យរដ្ឋបាលឃុំ សង្កាត់ ប្រើប្រាស់វិក្កយបត្រដែលមានលេខកូដ សម្រាប់បង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ, ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម និងចំណូលមិនមែនសារពើពន្ធដទៃទៀត)។

២. នៅដំណាក់កាលទី២ ជំហានទី៣ រដ្ឋបាលឃុំ សង្កាត់ ទូទាំងប្រទេស នឹងត្រូវអនុវត្តការកត់ត្រា និងបង់ចំណូលតាមរយៈប្រព័ន្ធ NRMIS។

៣. បេឡាករ នៃធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ត្រូវបញ្ចូលលេខវិក្កយបត្រ ដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS ទៅក្នុងបង្កាន់ដៃបង់ប្រាក់ (កន្លែងបរិយាយ/អត្ថន័យនៃការបង់ចំណូល) ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្ទៀងផ្ទាត់ប្រភពចំណូលជាមួយរដ្ឋបាលឃុំ សង្កាត់។

៤. ក្នុងករណីរដ្ឋបាលឃុំ សង្កាត់ ឬ អ្នកជាប់កាតព្វកិច្ចបង់ចំណូលផ្សេងទៀត ដែលបង់ចំណូលមិនមែនសារពើពន្ធ ដោយពុំមានលេខកូដទេនោះ បេឡាករ នៃធនាគារពាណិជ្ជដៃគូ និង/ឬគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ មិនត្រូវទទួលចំណូលទាំងនោះឡើយ។

៥. ធនាគារពាណិជ្ជដៃគូ និង/ឬគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ត្រូវទទួលសាច់ប្រាក់ទៅតាមចំនួនទឹកប្រាក់នៅលើវិក្កយបត្រដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ការរៀបចំលេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម និងចំណូលមិនមែនសារពើពន្ធដទៃទៀត) នៅរដ្ឋបាលឃុំ សង្កាត់ ត្រូវបានកំណត់ជាទម្រង់ ដូចខាងក្រោម÷

១.ចំណូលពីសេវារដ្ឋបាល (សេវារដ្ឋបាលផ្ទាល់របស់រដ្ឋបាលឃុំ សង្កាត់) ÷ **9XX-TT-9999**

២.ចំណូលក្រៅពីសេវារដ្ឋបាល (ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម និងចំណូលមិនមែនសារពើពន្ធដទៃទៀត) ÷ **9XX-PP-TT-9999**។

❖ **<u>កំណត់សម្គាល់</u>** ÷

- XX : 01 សម្គាល់រាជធានី ខេត្ត, 02 សម្គាល់ក្រុង ស្រុក ខណ្ឌ និង 03 សម្គាល់ឃុំ សង្កាត់
- PP : កូដសម្គាល់ភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្ត
- TT : ប្រភេទចំណូល (01 សេវាសាធារណៈ, 02 ការជួល, 03 ភាគលាភ, 04 ចំណូលពីកាតព្វកិច្ចកាស៊ីណូ, 05 សម្បទាន, 06 ផលនេសាទ, 07 ចំណូលពីអាកាសចរស៊ីវិល, 08 ផ្សេងៗ, 09 ពិន័យ និង 10 ចំណូលពីកាតព្វកិច្ចឆ្នោត)
- 9999 : លេខរៀងចំណូល។

➢ <u>ឧទាហរណ៍ទី១</u>÷ ចំណូលពីសេវារដ្ឋបាលផ្ទាល់ របស់រដ្ឋបាលឃុំ សង្កាត់

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 903<u>01</u>0001។

- 903 = សម្គាល់ចំណូលរបស់រដ្ឋបាលឃុំ សង្កាត់
- 01 = សម្គាល់ប្រភេទចំណូលពីសេវាសាធារណៈ
- 0001 = សម្គាល់លេខរៀងចំណូលពីសេវាសាធារណៈ (លេខរៀងទី ១)។

*ខ្លឹមសារ÷ ការចេញលិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់។*

➢ <u>ឧទាហរណ៍ទី២</u>÷ ចំណូលពីការបង់សំណែសចំណាយឆ្លងឆ្នាំ របស់រដ្ឋបាលឃុំ សង្កាត់

**សេចក្តីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 90301<u>08</u>0001។

- 903 = សម្គាល់ចំណូលរបស់រដ្ឋបាលឃុំ សង្កាត់
- 01 = កូដសម្គាល់ភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្ត (រដ្ឋបាលខេត្តបន្ទាយមានជ័យ)
- 08 = សម្គាល់ប្រភេទចំណូលផ្សេងៗ
- 0001 = សម្គាល់លេខរៀងចំណូលផ្សេងៗ (លេខរៀងទី ១)។

*ខ្លឹមសារ÷ រដ្ឋបាលឃុំ នៃខេត្តបន្ទាយមានជ័យ បង់ចំណូលពីសំណែសចំណាយឆ្លងឆ្នាំ។*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ធនាគារពាណិជ្ជដៃគូនិងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ជ្រាបនិងផ្តល់កិច្ចសហការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន÷</u>**
- ធនាគារជាតិ នៃ កម្ពុជា
- ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
- ធនាគារ ឯកទេសរីង (ខេមបូឌា) លីមីធីត
- ធនាគារ វឌ្ឍនៈ
- ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់
- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
- គ្រឹះស្ថានហិរញ្ញវត្ថុដៃគូ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ